00943162

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 08 / 2013
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé: UCH ARUN

002/19-09-2007-ECCC/TC
E1/206

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣

## សវនាការលើអង្គសេចក្ដី-ថ្ងៃ ១៩៣

រៀបចំដោយ: **ឌុច ផារី** និង **Matteo CRIPPA**

---

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោក Matteo CRIPPA, លោក ឌុច ផារី, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Keith REYNOR, លោក Tarik ABDULHAK, លោក ច័ន្ទ តារាវស្មី |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក សុន អរុណ, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU- |

| |
|---|
| FORT, លោក ហុង គីមសួន, លោស្រី ស៊ិន សុវ៉ន, |
| សាក្សី៖ លោកស្រី សូ សុជាតិ (TCW-673), លោក ស៊ឹម ហោ ហៅ ថាត (TCW-648) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ិច អារុណ, លោកស្រី សួ សុធារី |
| ផ្សេងៗ៖ កញ្ញា Elburg VAN BOETZELAER |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៥៥ | បញ្ចប់ម៉ោង៖ ១១.២០ |
| សម្រាកពិសាអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.០០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៥ ម៉ោង និង ១៥ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការបន្តស្តាប់សក្ខីកម្មសាក្សី សូ សុជាតិ (TCW-673) | តំណាងសហព្រះរាជអាជ្ញា | ០៩.០៥ | ០៩.៤៩ |
| | សហមេធាវីតំណាង/ដេណី | ០៩.៥០ | ១០.២៨ |
| | អង្គជំនុំជម្រះ និង សាក្សី | ១០.២៩ | ១០.៣៧ |
| ការពិភាក្សាអំពីភាពអាចទទួលយកបាននៃឯកសារ E282.1.19 និង E282.1.22 | មេធាវីការពារក្តី ខៀវ សំផន | ៩.១០ | ៩.១០ |
| | សហព្រះរាជអាជ្ញា | ៩.១០ | ៩.១១ |
| | មេធាវីការពារក្តី ខៀវ សំផន | ៩.១១ | ៩.១២ |
| | មេធាវីការពារក្តី នួន ជា | ៩.១៤ | ៩.១៦ |
| សំណើសុំឲ្យដាក់វិន័យដល់មេធាវីជាតិការពារឲ្យលោក ខៀវ សំផន | សហព្រះរាជអាជ្ញា | ១០.៣៧ | ១០.៤៥ |
| | មេធាវីការពារក្តី ខៀវ សំផន | ១០.៤៦ | ១០.៥២ |
| | មេធាវីការពារក្តី នួន ជា | ១០.៥២ | ១០.៥៣ |
| ការស្តាប់នូវសក្ខីកម្មរបស់សាក្សី ស៊ឹម ហោ (TCW-648) | អង្គជំនុំជម្រះ | ១១.២៣ | ១១.៣២ |
| | សហព្រះរាជអាជ្ញា | ១១.៣២ | ១៥.២០ |
| | សហមេធាវីតំណាង/ដេណី | ១៥.២១ | ១៥.៥៨ |
| ការពិភាក្សាអំពីកាលវិភាគសវនាការ | អង្គជំនុំជម្រះ | ១៥.៥៩ | ១៦.០១ |

| | | | |
|---|---|---|---|
| | មេធាវីការពារក្ដី ខៀវ សំផន<br>មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ | ១៦.០១<br>១៦.០១<br>១៦.០៣ | ១៦.០១<br>១៦.០៣<br>១៦.០៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

អនុលោមតាមសេចក្តីសម្រេចលើកទីពីរស្តីពីបញ្ហាសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ ជនជាប់ចោទ នួន ជា ត្រូវបានអនុញ្ញាតិឲ្យមានវត្តមាននៅត្រឹមបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ អនុលោមតាមវិធាន ៨១ (៥) ។

**ការបន្តស្តាប់នូវសក្ខីកម្មរបស់សាក្សី សូ សុជាតិ (TCW-673)**

តំណាងសហព្រះរាជអាជ្ញាបន្តនិងបញ្ចប់ការតាំងសំណួរដល់សាក្សីដល់សាក្សី សូ សុជាតិ (TCW-673) ។ បន្ទាប់មកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាំងសំណួរដល់សាក្សី សូ សុជាតិ (TCW-673) ។

**ការពិភាក្សាអំពីភាពអាចទទួលយកបាននៃឯកសារ E282.1.19 និង E282.1.22**

មេធាវីការពារជនជាប់ចោទ ខៀវ សំផន ជម្ទាស់ទៅនឹងការយោងលើឯកសារ E282.1.19 និង E282.1.22។ សហព្រះរាជអាជ្ញាលើកឡើងថាឯកសារទាំងនេះគឺត្រូវបានបង្ហាញជាឯកសារសាធារណៈដោយ Wikileaks។ អង្គជំនុំជម្រះណែនាំដល់សហព្រះរាជអាជ្ញាមិនឲ្យសួរសំណួរទាក់ទងនឹងខ្លឹមសារនៃឯកសារ។

**សំណើសុំឲ្យដាក់វិន័យដល់មេធាវីជាតិការពារឲ្យលោក ខៀវ សំផន**

សហព្រះរាជអាជ្ញាស្នើសុំឲ្យដាក់វិន័យដល់មេធាវីជាតិការពារឲ្យលោក ខៀវ សំផន ទាក់ទងនិងវិធីសាស្ត្ររបស់លោកមេធាវីក្នុងការសួរសំណួរដល់សាក្សី សូ សុជាតិ ព្រោះវិធីសាស្ត្រដែលគាត់ប្រើនោះមិនស្របនឹងបទដ្ឋានដែលមានចែងក្នុងវិធាន (វិធាន ៣៥)។ សហព្រះរាជអាជ្ញាស្នើដាក់ពិន័យ ប្រមានជាផ្លូវការ និងរាយការណ៍អំពីអាកប្បកិរិយារបស់មេធាវីការពារក្តីជាតិរបស់លោក ខៀវ សំផន ទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

**ការស្តាប់នូវសក្ខីកម្មរបស់សាក្សី ស៊ុម ហោ (TCW-648)**

អង្គជំនុំជម្រះសាលាដំបូងតាំងសំណួរបឋមដល់សាក្សី បន្ទាប់មក សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាំងសំណួរដល់សាក្សី ស៊ឹម ហោ ។

**ការពិភាក្សាអំពីកាលវិភាគសវនាការ**

អង្គជំនុំជម្រះជូនដំណឹងដល់ភាគីទាក់ទងនឹងការផ្លាស់ប្តូកាលវិភាគនៃការស្តាប់សក្ខីកម្មរបស់សាក្សី និងកិច្ចប្រជុំរៀបចំសវនាការ។ កិច្ចប្រជុំរៀបចំសវនាការនឹងប្រព្រឹត្តិទៅនៅព្រឹកថ្ងៃព្រហស្បត្តិ៍ ហើយការស្តាប់សក្ខីកម្មរបស់សាក្សីនឹងបន្តនៅពេលរសៀល ។ ជនជាប់ចោទ នួន ជា និង ខៀវ សំផន ស្នើសុំមិនចូលរួមក្នុងកិច្ចប្រជុំនេះ ។

ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖

- បង្គាប់ឲ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ជូនសាក្សី សូ សុជាតិ (TCW-673) និង លោក ស៊ឹម ហោ ហៅ ថាត (TCW-648) ត្រឡប់ទៅគេហដ្ឋានរបស់គាត់វិញ និងបង្គាប់ឲ្យនាំសាក្សី ស៊ឹម ហោ ហៅ ថាត (TCW-648) ត្រឡប់មកសវនាការវិញនៅថ្ងៃទី ១៣ មិថុនា ២០១៣ ឲ្យបានមុនម៉ោង ០៩.០០ នាទី ព្រឹក។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងឲ្យនាំខ្លួនជនជាប់ចោទ ខៀវ សំផន ត្រឡប់មកបន្ទប់សវនាការវិញ ចំណែកជនជាប់ចោទ នួន ជា មកកាន់បន្ទប់ឃុំខ្លួននៅពីខាងក្រោមសាលសវនាការនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឲ្យបានមុនម៉ោង ០៩ ព្រឹក។

ដីកាសម្រាប់ការលើកវារកាលសវនាការ

សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ វេលាម៉ោង ៩.០០ ព្រឹក ។

ភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣

| | |
|---|---|
| ក្រឡាបញ្ជី | ក្រឡាបញ្ជី |
| ឌុច ឆាវី | Matteo CRIPPA |